ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

RAC Ratings

**ក្រុមហ៊ុន រេតធីង អេជេនស៊ី អហ្វ (ខេមបូឌា)ម.ក**

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០២៣ ក្រុមប្រឹក្សាភិបាលនៃសមាគមទីភ្នាក់ងារវាយតម្លៃចំណាត់ថ្នាក់ឥណទានអាស៊ី (ACRAA) បានអនុម័តពាក្យសុំចូលជាសមាជិករបស់ក្រុមហ៊ុន រេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក (RAC) ។

គួរបញ្ជាក់ផងដែរថា ACRAA ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០១ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ដោយមានកិច្ចសហប្រតិបត្តិការ និងការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដើម្បីនាំយកភ្នាក់ងារវាយតម្លៃចំណាត់ថ្នាក់ឥណទានក្នុងស្រុកទៅជាកិច្ចសហប្រតិបត្តិការក្នុងតំបន់ ។ គោលបំណងរបស់សមាគមនេះគឺ «ដើម្បីលើកកម្ពស់ការទទួលយកការអនុវត្តល្អបំផុត និងស្តង់ដាររួមនៅទូទាំងអាស៊ី ក៏ដូចជាការចូលរួមអភិវឌ្ឍន៍ទីផ្សារមូលធននៅអាស៊ីនិងការវិនិយោគឆ្លងព្រំដែនទូទាំងតំបន់» *។ បច្ចុប្បន្ន ACRAA មានសមាជិកចំនួន ២៨ មកពី ១៣ ប្រទេស។

តាមរយៈការចូលរួមជាមួយនឹងភ្នាក់ងារវាយតម្លៃចំណាត់ថ្នាក់ឥណទានក្នុងតំបន់របស់ក្រុមហ៊ុន រេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក នឹងទទួលបានអត្ថប្រយោជន៍ពីការផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ និងជំនាញ។ បន្ថែមពីនេះការបញ្ជូនព័ត៌មានអំពីទីផ្សារពីអ្នកបោះផ្សាយមូលបត្របំណុល ទៅកាន់វិនិយោគិនតាមរយៈការផ្តល់ចំណាត់ថ្នាក់លទ្ធភាពសងរបស់ក្រុមហ៊ុន រេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក នឹងរួមចំណែកដល់ការពង្រីកទីផ្សារមូលធនកម្ពុជា និងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជាផងដែរ។

រាជធានីភ្នំពេញ ថ្ងៃពុធ ៣រោច ខែបឋមសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ត្រូវនឹងថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០២៣
**ក្រុមហ៊ុន រេតធីង អេជេនស៊ី អហ្វ (ខេមបូឌា)ម.ក**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន រេតធីង អេជេនស៊ី អហ្វ (ខេមបូឌា).ម.ក RATING AGENCY OF (CAMBODIA) PLC. KINGDOM OF CAMBODIA

* https://aric.adb.org/initiative/association-of-credit-rating-agencies-in-asia

អាសយដ្ឋាន៖ អគារលេខ២៤៦ (ជាន់ទី២), មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246 (2nd floor), Preah Monivong Blvd (93), Village 10, Sangkat Boeung Rang, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរស័ព្ទ៖ (៨៥៥)១៧ ៣៩២ ៧៧៧
Phone: (+855)17 392 777
www.ratingagencyofcambodia.com.kh
សារអេឡិចត្រូនិច info@ratingagencyofcambodia.com.kh
Email: info@ratingagencyofcambodia.com.kh